JobAccess
Driving disability employment

# បណ្ណ័ព័ត៌មាន

# តើអ្នកជានិយោជកដែលចង់បានបុគ្គលិកធ្វើការវ័យក្មេង ឬទេ?

មនុស្សដែលត្រូវនឹងសេចក្តីត្រូវការរបស់ក្រុមហ៊ុនរបស់អ្នក អាចជាមនុស្សវ័យក្មេងដែលមានពិការភាព។
មានសេវាឥតគិតថ្លៃផ្តល់ដោយរដ្ឋាភិបាលអូស្ត្រាលីមួយចំនួនដែលអាចជួយអោយអ្នកស្វែងរក
និងរក្សាបុគ្គលិកវ័យក្មេងដែលមានពិការភាព ។

**សេវាការងារសម្រាប់ជនពិការ** អាចផ្តល់អោយអ្នកនូវសេវាដោយឥតគិតថ្លៃជាច្រើន
រួមទាំងការជួយក្នុងការជ្រើសរើស និងរក្សាបុគ្គលិកវ័យក្មេងដែលមានពិការភាព ។
អ្នកផ្តល់សេវាទាំងនេះគឺជាអ្នកមានចុះកិច្ចសន្យាផ្តល់សេវារដ្ឋាភិបាល
និងជួយបណ្តាជនដែលមានសិទ្ធិទទួលដែលមានពិការភាព របួស ឬលក្ខណៈសុខភាពដើម្បីស្វែងរក
និងរក្សាការងារ ។

**កម្មវិធីអភិវឌ្ឍសហគមន៍** (Community Development Programme) (CDP)
អាចជួយអ្នកក្នុងការស្វែងរកបុគ្គលិកដែលត្រូវចំពោះអ្នក
ប្រសិនបើអ្នករស់នៅតំបន់ដាច់ស្រយាលក្នុងប្រទេសអូស្ត្រាលី
និងកំពុងស្វែងរកបុគ្គលិកវ័យក្មេងដែលមានពិការភាព។

**កម្មវិធីហ្វឹកហ្វឺនជំនាញការងារ  និងកម្មវិធីបន្ទាត់បង្រៀនធ្វើការ** អាចជាវិធីដ៏ល្អមួយក្នុងការទាក់ទាញ
បណ្តុះបណ្តាល
និងរក្សាបុគ្គលិកដើម្បីឆ្លើយតបទៅនឹងតម្រូវការនានារបស់អាជីវកម្មនិងឧស្សាហកម្មរបស់លោកអ្នក ។

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**

- **កម្មវិធីហ្វឹកហ្វឺនជំនាញការងារអូស្ត្រាលី** រចនាឡើងដើម្បីមានលទ្ធភាពបត់បែនបាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានារបស់អ្នក និងបុគ្គលិករបស់អ្នក ។
- **ការជួយគាំទ្រប្រាក់បៀវត្សដល់អ្នកហ្វឹកហ្វឺនជំនាញការងារពិការអូស្ត្រាលី (Disabled Australian Apprentice Wage Support) (DAAWS)**

  **គឺជាប្រាក់ឧបត្ថម្ភមួយដែលអាចជួយលោកអ្នកដើម្បីអោយអ្នកហ្វឹកហ្វឺនដែលមានពិការភាពអាចចូលរួមយ៉ាងពេញលេញក្នុងការហ្វឹកហ្វឺនរបស់ពួកគេ ។** DAAWS **ក៏មានសម្រាប់ផ្តល់ជូនអ្នកដែរ ប្រសិនបើសិស្ស អូស្ត្រាលីរបស់អ្នកក្លាយជាជនពិការក្នុងអំឡុងពេលហ្វឹកហ្វឺន និងហាត់រៀន ។**

**បើអ្នកចង់បានព័ត៌មានបន្ថែមស្តីអំពីសេវាទាំងនេះ អ្នកអាចមើលគេហទំព័រ** JobAccess **នៅ** www.jobaccess.gov.au **ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់** JobAccess **តាមរយៈលេខ**1800 464 800 – **ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។**